**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ី ជីនចាវ** (SHI JINZHAO) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៥ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១២១៤-១១១៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦*

លេខ: ១០៩៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៦/ ១១០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហួង ហួនម៉េង** (HUANG HUANMING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៦៣ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.៧.១៦១៤.១១៤០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦

លេខ:១០៩០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១២១៦/១១០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជឹង កាំហ្វៃឌុកឡាស** (CHEUNG KAM FAI DOUGLAS) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៨០ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ជឹង ឌុកឡាស** (CHEUNG DOUGLAS)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧ . ១៦១៤ . ១១២១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦*

លេខ:១០៩១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៥៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**<u>សម្រេច</u>**

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣ ០៩១ ៦០០ ០០០ រៀល (បីប៊ីលានកៅសិបមួយលានប្រាំមួយរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនក្រសួងព្រះបរមរាជវាំង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយរៀបចំព្រះរាជដំណើរដ៏ខ្ពង់ខ្ពស់ថ្វាយ**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជវរោកាសស្តេចនឹងយាងគង់ប្រថាប់សម្រាកព្រះកាយឆ្លងឆ្នាំសកល នៅខេត្តព្រះសីហនុចាប់ពីថ្ងៃទី ៣០-៣១ ខែ ធ្នូ ឆ្នាំ ២០១៦ និងថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៧។

**មាត្រា៣._**

រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៥ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក ៦១ (សេវាកម្ម) មកជំពូក ៦០ (ការទិញ) ចំនួន ១៦៤ ០០០ ០០០ រៀល ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៤៣០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គលេខាធិការរាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ចំនួន៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាល កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | |
|---|---|---|
| ១-ឯកឧត្តម | **ហេង សិក្សា** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល |
| ២-លោក | **ហេង នីរ៉ាដូ** | ជំនួយការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |
| ៣-លោក | **ញ៉ែម ម៉ាណេត** | មន្ត្រីអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |
| ៤-លោក | **គុណ ពេជ្រយ៉ាតសេន** | មន្ត្រីអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |

**ខ-មេដាយសំរឹទ្ធការងារ**

| | | |
|---|---|---|
| ១-លោក | **ទេព សានិត** | មន្ត្រីអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |
| ២-លោក | **រិន រដ្ឋា** | មន្ត្រីអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |
| ៣-លោក | **ហ៊ី រដ្ឋា** | មន្ត្រីអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |
| ៤-លោក | **មុត ខ្វាន់ សំអាតវាសនា** | មន្ត្រីអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អគ្គលេខាធិការរាជរដ្ឋាភិបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ១៧១០.១៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ** ជូនសប្បុរសជនកូរ៉េ ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងផ្លូវបេតុង១ខ្សែប្រវែង ២០០x២០ម៉ែត្រ និងជួសជុលអាគារស្នាក់នៅរបស់សិស្ស នៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺន និងជួសជុលបញ្ជូនសារ អស់ទឹកប្រាក់ចំនួន ៦១,៥០០ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-លោក | **លី** | **តេកស៊ូ** | LEE TAEKSOO | នាយក ក្រុមហ៊ុនជិនហាអ៊ីនដាស្ទ្រី JINHAE INDUSTRY CO.LTD សាធារណរដ្ឋកូរ៉េ |
| ២-លោកស្រី | **គីម** | **ហេយ៉ុង** | KIM HAEYONG | នាយករង ក្រុមហ៊ុនជិនហាអ៊ីនដាស្ទ្រី JINHAE INDUSTRY CO.LTD សាធារណរដ្ឋកូរ៉េ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។[illegible]

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៧២១១...អនក្រ.តតត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.**-បំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ចំនួន ២៧គ្រឿង ជូននាយទាហាន នៃកងទ័ពប្រជាជនវៀតណាម ចំនួន ២៧រូប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការជួយបណ្តុះបណ្តាល និងបំប៉នជំនាញផ្សេងៗ ដល់នាយទាហាន និងនាយទាហានរង នៃកងយោធពលខេមរភូមិន្ទ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី បណ្ឌិត | ទ្រីញ | វ៉ាន់ណយ | Trinh Van Noi |
| ២-វរសេនីយ៍ឯក បណ្ឌិត | លឿង | មីញកាវ | Luong Minh Cao |
| ៣-វរសេនីយ៍ឯក | វ៉ូ | សួនឃ្វេ | Vu Xuan Que |

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន | កុងស៊ឺន | Nguyen Cong Son |
| ២-វរសេនីយ៍ឯក អនុបណ្ឌិត | ទ្រឹន | ញ៉ានតាយ | Tran Nhan Tai |
| ៣-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន | គួកយ៉ាញ | Nguyen Quoc Danh |
| ៤-វរសេនីយ៍ឯក | ទ្រីញ | ញ៉ានខុន | Trinh Nhan Khon |
| ៥-វរសេនីយ៍ឯក បណ្ឌិត | ឡេ | ស៊ីញដុង | Le Sinh Dong |
| ៦-វរសេនីយ៍ឯក អនុបណ្ឌិត | វ៉ី | សួននីញ | Vo Xuan Ninh |

| | | |
|---|---|---|
| ៨-វរសេនីយ៍ឯក អនុបណ្ឌិត | យឿង ង៉ុកប៊ីញ | Thsduong Ngoc Binh |
| ៩-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន ង៉ុកជី | Nguyen Ngoc Chi |
| ១០-វរសេនីយ៍ឯក បណ្ឌិត | ញ៉ាម វ៉ាន់ធី | Nham Van Thuy |
| ១១-វរសេនីយ៍ឯក បណ្ឌិត | ទ្រីញ ខ្វាងធីន | Trinh Quang Than |
| ១២-វរសេនីយ៍ឯក បណ្ឌិត | វ៉ វ៉ាន់ហ្វូ | Vo Van Phu |
| ១៣-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន កាញ់វីញ | Nguyen Canh Vinh |
| ១៤-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន ញីហូយ | Nguyen Nhu Hoi |
| ១៥-វរសេនីយ៍ឯក | ង្វៀន វ៉ាន់ហ្វុង | Nguyen Van Phong |
| ១៦-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន បាដាន | Nguyen Ba Dan |
| ១៧-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន គួកអ៊ី | Nguyen Quo Uy |
| ១៨-វរសេនីយ៍ឯក បណ្ឌិត | វ៉ូ វ៉ាន់ទ្រុង | Vu Van Trung |
| ១៩-វរសេនីយ៍ឯក បណ្ឌិត | ដាំង ថេរទ្រៀន | Dang The Truyen |
| ២០-វរសេនីយ៍ឯក បណ្ឌិត | ង្វៀន ង៉ុកឡុង | Nguyen Ngoc Long |
| ២១-វរសេនីយ៍ឯក | ង្វៀន សួនហ៉យ | Nguyen Xuan Hoai |
| ២២-វរសេនីយ៍ឯកបម្រុង | ឡេ វ៉ាន់គី | Le Van cu |
| ២៣-វរសេនីយ៍ឯកបម្រុង | ង្វៀន ឌីញលីញ | Nguyen Dinh Linh |
| ២៤-វរសេនីយ៍ទោ | ដូ កាកដុង | Do cac Dong |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ១២១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន៩រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តសិរីសោភ័ណ្ឌ ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **គយ ហ៊ត** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ១០.២២៥ ដុល្លារ |
| ២-លោក | **ជា ម៉េងឆាន** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ១០.១១០ ដុល្លារ |
| ៣-លោក | **ជា ម៉េងតៃ** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ១០.១០៤ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **ហូ ឈុនអ៊ី** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ៦.២១០ ដុល្លារ |
| ២-លោក | **ទី ចិត្តត្រា** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ៦.១២០ ដុល្លារ |
| ៣-លោក | **ខិន ឡាក់** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ៦.១១០ ដុល្លារ |
| ៤-លោក | **ហួត គង់** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ៦.០៩០ ដុល្លារ |
| ៥-អ្នកស្រី | **ជៀប វណ្ណា** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ៦.០៥០ ដុល្លារ |
| ៦-អ្នកស្រី | **ប៊ុន យាន** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ៦.០៤៥ ដុល្លារ |

**មាត្រា២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ :** ១៤១៤...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**- បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេន និងជូនសប្បុរសជន ចំនួន៤រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តសិរីសោភ័ណ្ឌ ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កន្លងមក ដូចមាននាយព្រះនាមនិងនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ **ជា** | **ចាន់រ៉ាម៉ូ** | ចៅអធិការវត្តសិរីសោភ័ណ្ឌ | |
| ២-ឯកឧត្តម **ខ្វិច** | **កែវ** | ទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ងួន ញ៉ិល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ | ថវិកាចំនួន ៦២.២០០ ដុល្លារ |
| ៣-លោក **ឃឹម** | **សុខ** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ៦១.២០០ ដុល្លារ |
| ៤-លោក **ជា** | **រដ្ឋា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៦០.៩០០ ដុល្លារ |

**មាត្រា២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២១៥ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការជូនមេដាយ សហមេត្រី និង មេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១-**

ត្រូវបានបំពាក់មេដាយ សហមេត្រី និងមេដាយ ស្ថាបនាជាតិ ជូនសប្បុរសជន និងមន្ត្រីនគរបាលជាតិជាន់ខ្ពស់ ដែលបានបរិច្ចាគនូវថវិកាផ្ទាល់ខ្លួនក្នុងការកសាង និងស្ថាបនាអាគារប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន និងកន្លែងស្នាក់នៅសម្រាប់មន្ត្រីនគរបាលជាតិ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយ សហមេត្រី ថ្នាក់ធិបឌិន្ទ:**

១- លោក NGO HONG YEN ប្រធាននាយកកិច្ចការផ្ទៃក្នុង ខេត្ត AN GIANG

២- លោក NGUYEN THANH QUAN ប្រធានក្រុមប្រឹក្សាស្រុក TINH BIEN ខេត្ត AN GIANG

**ខ-មេដាយ សហមេត្រី ថ្នាក់សេនា:**

១- លោក HO VAN THANH ប្រធានក្រុមហ៊ុន HUNG NGUYEN

២- លោក HUYNH KIM VINH

៣- លោក NGUYEN VAN CON

**គ-មេដាយ មាស ស្ថាបនាជាតិ:**

១- លោកឧត្តមសេនីយ៍ត្រី **សុខ សំណាង** អនុប្រធាននាយកដ្ឋានច្រកទ្វារទី២ និងជានាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

២- លោក **ភាន់ រ៉ា** ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

៣- លោកវរសេនីយ៍ឯក **ហោ សំអុី** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

៤- លោកវរសេនីយ៍ទោ **ញឹម សុខលី** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

៥- លោកវរសេនីយ៍ទោ **ម៉ិន ចន្ថា** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

៦- លោកវរសេនីយ៍ទោ **ទ្រិន ឆាយ** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

៧- លោកវរសេនីយ៍ត្រី **ធឹម រតនៈ** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

**ឃ-មេដាយ ប្រាក់ ស្ថាបនាជាតិ:**

១- លោកវរសេនីយ៍ត្រី **មាច ផាត** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

២-លោកវរសេនីយ៍ត្រី**សាន់ ចេងសៀង** នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន

**មាត្រា ២-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួល បន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៦ សរណន

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបលើកទី៣៤ ទិវាជនពិការអន្តរជាតិ និងខួបលើកទី១៨ ទិវាជនពិការកម្ពុជា ក្រោមប្រធានបទ "ផ្តល់អានុភាព និងសិទ្ធិអំណាចដល់ជនពិការ ក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព"

## ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៦

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ នៅថ្ងៃទី០៣ ខែធ្នូ ដើម្បីរំលឹកដល់ការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលលើវិស័យពិការភាព ជាពិសេសសុខុមាលភាពបងប្អូនជនពិការកម្ពុជា ស្របតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។

ទិវាជនពិការអន្តរជាតិត្រូវបានប្រារព្ធឡើង ដើម្បីរំលឹកអំពីការតស៊ូទាមទារសិទ្ធិចូលរួមក្នុងសង្គមរបស់ជនពិការប្រមាណ ១ប៊ីលាននាក់ ស្មើនឹងចំនួន ១៥% នៃប្រជាជនសរុបនៅក្នុងពិភពលោក ដែលជាជនបាត់បង់កាយសម្បទា កាយវិញ្ញាណ និងសតិបញ្ញា ដែលតែងតែជួបប្រទះឧបសគ្គរាំងស្ទះក្នុងជីវិត តាំងពីឆ្នាំ១៩៥០ នៅសហរដ្ឋអាមេរិក និងអឺរ៉ុប សំដៅធ្វើការផ្លាស់ប្តូរនូវស្ថានភាពរស់នៅរបស់ពួកគេ និងបង្កើនការយល់ដឹងអំពីបញ្ហាពិការភាព ដោយផ្តោតសំខាន់លើសិទ្ធិជនពិការ ព្រមទាំងការធ្វើសមាហរណកម្មជនពិការទៅក្នុងគ្រប់សកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និង កីឡា។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាប្រារព្ធទិវាជនពិការនេះឡើង ដើម្បីរំលឹកអំពីមហាវិនាសកម្មនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើន ក្នុងនោះរួមមានជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រា ព្រមទាំងគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។ ក្រៅពីនោះ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពវង្វេងគ្រោះមួយចំនួនទៀតដែលនាំឲ្យមានពិការភាពដូចជា គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា ជំងឺ និងមូលហេតុផ្សេងៗទៀត។

ដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំងដូចតទៅ៖

១.ទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ត្រូវប្រារព្ធក្រោមប្រធានបទ **"ផ្តល់អានុភាព និងសិទ្ធិអំណាចដល់ជនពិការក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព"**។

២.ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជន ឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូលឱ្យបានយល់ជ្រួតជ្រាបអំពីប្រវត្តិនៃទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ៣ធ្នូ។

៣.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទិញ ពិធីជួបសំណេះសំណាលជាមួយជនពិការ កម្មវិធីកម្សាន្តសប្បាយរបស់ជនពិការ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលនៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៤.ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា មូលនិធិជនពិការ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធត្រូវសហការរៀបចំពិធីមីទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់ជនពិការនៅរាជធានីភ្នំពេញ។

៥.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ ឯកជន ត្រូវរៀបចំចងបដា ពាក្យស្លោកដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ដែលមានខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព
- ផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកដើម្បីឃើញពីជាតុពិតរបស់ជនពិការ
- កាត់បន្ថយភាពក្រីក្ររបស់ជនពិការ តាមរយៈការផ្តល់ឱកាសការងារស្មើគ្នា
- រួមគ្នាអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់អនាគតយើង
- កែសម្រួលនិងរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបរិស្ថានគ្មានពិការភាព
- ជនពិការត្រូវការផ្តល់តម្លៃជាជាងការអាណិត

ទទួលបានសារាចរណែនាំ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជរាជធានី ខេត្តត្រូវរៀបចំចាត់តាំងអនុវត្តក្នុងស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០១ ផ.ក....

# ផែនការ

## ស្តីពី

## យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១

## រយៈពេល ៦ ខែ (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧)

កម្ពុជារក្សាបានកិត្តិយសល្អថា ជាប្រទេសមិនផលិតគ្រឿងញៀន ឬប្រភពនៃគ្រឿងញៀន ប៉ុន្តែនៅមានសកម្មភាពលួចលាក់នាំចូលគ្រឿងញៀនពីក្រៅប្រទេស តាមរបៀងព្រំដែនទិសឦសានប្រទេសនិងតាមជើងយន្តហោះ ជាពិសេសមកពីទ្វីបអាហ្វ្រិក និងអាមេរិកខាងត្បូងក្នុងគោលដៅដើម្បីបន្តនាំចេញទៅប្រទេសទី៣ និងមួយចំនួនទៀតសម្រាប់ទីផ្សារក្នុងប្រទេស។ ទន្ទឹមនេះ បានធ្វើការកត់សម្គាល់ឃើញថា និន្នាការចរាចរនិងជួញដូរគ្រឿងញៀនមិនមានការថយចុះ ជាក់ស្តែងក្នុងឆ្នាំ២០១៦នេះ នគរបាល និងកងរាជអាវុធហត្ថ បង្ក្រាបបាន ៤.១៩១ករណី (បទល្មើសប្រើប្រាស់១.១១២ករណី), ចាប់ជនសង្ស័យសរុប ៩.៨០២ នាក់ (អ្នកប្រើប្រាស់គ្រឿងញៀន ៣.៦១១នាក់) និងរឹបអូសគ្រឿងញៀនជាង ១៧៥គីឡូក្រាម៧៩៦ក្រាម។ កត្តានេះធ្វើឱ្យការប្រើប្រាស់គ្រឿងញៀនមានការកើនឡើង និងមានការរីករាលដាលគួរឱ្យបារម្ភ ពីទីក្រុងរហូតដល់ជនបទតំបន់ដាច់ស្រយាលមួយចំនួន (តាមតួលេខ នៃការធ្វើសម្រង់អ្នកញៀនគ្រឿងញៀនមានចំនួន ១៨.៥៥៤នាក់ កើនឡើង ៤.២៤២នាក់ ស្មើនឹង ២៩.៦៣% ធៀបនឹងពេលមុន)។ បញ្ហាគ្រឿងញៀនក៏បានជះឥទ្ធិពលដល់សកម្មភាពប្រព្រឹត្តបទល្មើសដែលកាន់តែមានចរិតសាហាវ ព្រៃផ្សៃ គិតទាំងករណីគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលមកពីអ្នកបើកបរប្រើប្រាស់គ្រឿងញៀន។

ដោយពិនិត្យឃើញថាឥទ្ធិពលនៃការផលិត ការចរាចរ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅលើពិភពលោក និងក្នុងតំបន់បាននិងកំពុងជះឥទ្ធិពលចំពោះព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ ផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដូចខាងក្រោម៖

### I. គោលការណ៍រួម

- បន្តចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព នូវច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទបញ្ជាលេខ ០១បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ខិតខំបង្ការ ទប់ស្កាត់មិនឱ្យគ្រឿងញៀនបង្កឥទ្ធិពលញាំញី បំផ្លិចបំផ្លាញសង្គមជាតិកម្ពុជា ជាពិសេសប្រឹងប្រែងសម្រេចការប្តេជ្ញាចិត្តថា កម្ពុជាជាប្រទេសគ្មានគ្រឿងញៀន និងរក្សាគ្រួសារនីមួយៗជា*គ្រួសារស្អាតស្អំគ្មានគ្រឿងញៀន* តាមទស្សនវិស័យ «*ចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន*»។

- អប់រំបំផុសចលនា លើកទឹកចិត្តឱ្យមានការចូលរួមកុះករពីគ្រប់សមាសភាពនៃសង្គម ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវជន យុវនារី សហការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងនោះយកចិត្តទុកដាក់ចំពោះការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ដោយត្រូវផ្តោតការយកចិត្តទុកដាក់គ្រប់គ្រងឱ្យបាននូវមុខសញ្ញាជួញដូរ ក៏ដូចជាធ្វើការងារអប់រំ ផ្សព្វផ្សាយអំពីគ្រោះថ្នាក់ដោយសារគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យបានទូលំទូលាយគ្រប់រូបភាព គ្រប់ទីកន្លែង ចំគោលដៅ និងចំមុខសញ្ញាងាយរងគ្រោះ ជាពិសេសសិស្សានុសិស្ស កម្មករ ពលករ សំដៅឱ្យពួកគាត់ចៀសឆ្ងាយពីគ្រឿងញៀន។

- ជំរុញអនុវត្តវិធានការច្បាប់ និងវិធានការរដ្ឋបាលឱ្យបានម៉ឺងម៉ាត់ និងដូចគ្នៀងរលឹម ក្នុងគោលដៅស្រាវជ្រាវរកឱ្យឃើញបណ្តាញអង្គការចាត់តាំងនៃក្រុមឧក្រិដ្ឋជនគ្រឿងញៀន ឧបាយកល សកម្មភាពទំនាក់ទំនង របៀបដឹកជញ្ជូន ព្រមទាំងលុបបំបាត់សកម្មភាពជួញដូរ ប្រើប្រាស់គ្រឿងញៀន ដើម្បីកាត់ផ្តាច់ការចរាចរគ្រឿងញៀនឆ្លងដែន និងបង្ក្រាបដោយម៉ឺងម៉ាត់ដល់ឫសគល់ប្រកបដោយប្រសិទ្ធភាព

- ខិតខំប្រមូលផ្តុំលើកកម្ពស់សមត្ថភាព លទ្ធភាពគ្រប់គ្រង ព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀនឱ្យបានប្រសើរថែមទៀត ដើម្បីទប់ស្កាត់ការរីករាលដាលចំនួនអ្នកញៀន បង្រួមទីផ្សារគ្រឿងញៀន និងរួមចំណែកកាត់បន្ថយបទល្មើសផ្សេងៗដែលជះឥទ្ធិពលពីគ្រឿងញៀន

- លើកកម្ពស់សមត្ថភាពបំពេញការងាររបស់មន្ត្រីអនុវត្តច្បាប់ទាំងលើវិស័យជំនាញ និងនីតិវិធីក្នុងការអនុវត្តន៍ឱ្យបានជាប្រចាំ ព្រមទាំងត្រូវបង្កើតឱ្យមានកិច្ចសហការគ្នាល្អជាមួយស្ថាប័នអយ្យការ និងតុលាការ ដើម្បីរិះរកវិធីដាក់បន្ទុកបន្ថែមស្ថានទម្ងន់ទោសដល់ពួកឧក្រិដ្ឋជនគ្រឿងញៀនឱ្យបានម៉ឺងម៉ាត់តាមច្បាប់ ។ ត្រូវពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាអង្គភាពប្រឆាំងគ្រឿងញៀនរបស់ប្រទេសជាដៃគូឱ្យបានទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ពីចម្ងាយ ទទួលព័ត៌មានបម្រើឱ្យការបង្ក្រាប និងដកបទពិសោធពីគ្នាទៅវិញទៅមក ។

## II. **វិធានការ**

### **១. វិធានការអប់រំ:**

អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីស្នូលក្នុងការផ្សព្វផ្សាយ អប់រំតាមគ្រប់រូបភាព និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការលើកកម្ពស់ការយល់ដឹង នឹងចូលរួមពីសំណាក់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ដូចជា៖

- អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវរៀបចំក្រុមការងារវេទិកាតុមូល ដើម្បីធ្វើការអប់រំខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមកម្មវិធីទូរទស្សន៍ វិទ្យុនិងបណ្តាញសង្គមឲ្យបានជារៀងរាល់ថ្ងៃ

- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពង្រឹងនិងពង្រីកសកម្មភាពអប់រំប្រឆាំងគ្រឿងញៀនជាប្រចាំ សម្រាប់ឱ្យសិស្សានុសិស្សរៀនសូត្រនៅតាមគ្រប់កម្រិត គ្រប់គ្រឹះស្ថានសិក្សា ស្របតាមកម្មវិធីដែលក្រសួងបានរៀបចំ

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំកម្មវិធីអប់រំប្រឆាំងគ្រឿងញៀន ដល់កម្មករនៅតាមរោងចក្រ សហគ្រាស សិប្បកម្ម និងការដ្ឋានសំណង់នានា

- ក្រសួងព័ត៌មាន ត្រូវកំណត់ឱ្យគ្រប់ស្ថានីយទូរទស្សន៍ ស្ថានីយវិទ្យុ បណ្តាញផ្សាយព័ត៌មានសង្គម មានកម្មវិធីផ្សាយអំពីការអប់រំគ្រឿងញៀនជាក់លាក់សម្រាប់ថ្ងៃនីមួយៗ

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវណែនាំឲ្យក្រុមហ៊ុនទូរស័ព្ទផ្ញើសារអប់រំប្រឆាំងគ្រឿងញៀន ដល់អ្នកប្រើប្រាស់ឱ្យបានញឹកញាប់

- ក្រសួងទេសចរណ៍ត្រូវកំណត់ឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងគោលដៅដែលពាក់ព័ន្ធនឹងទេសចរណ៍ រួមទាំងកន្លែងកំសាន្តសប្បាយនានា តាំង បិទ នូវខ្លឹមសារអប់រំ ឬការហាមចរាចរ ជួញដូរ ប្រើប្រាស់គ្រឿងញៀន

- ក្រសួងធម្មការ និងសាសនា ត្រូវចូលរួមដើម្បីរៀបចំបញ្ច្រៀបកម្មវិធីអប់រំប្រឆាំងគ្រឿងញៀន តាមរយៈកម្មវិធីសាសនា និងការទេសនារបស់ព្រះសង្ឃជូនពុទ្ធបរិស័ទ

- គណៈបញ្ជាការឯកភាពរដ្ឋបាល និងជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងក្រុមការងារថ្នាក់ជាតិគ្រប់ថ្នាក់ ត្រូវរៀបចំឱ្យមានព្រឹត្តិការណ៍ផ្សព្វផ្សាយ អប់រំប្រឆាំងគ្រឿងញៀនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមួយកន្លែងឱ្យបានយ៉ាងតិច ០២លើកក្នុងមួយខែ តាមរយៈវេទិកាសាធារណៈ ឬវេទិកាផ្សេងៗទៀត។

**២. វិធានការរដ្ឋបាល**

- គណៈបញ្ជាការឯកភាពរដ្ឋបាល និងជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវដំឡើងបញ្ជី និងក្តាប់ឱ្យបាននូវគោលដៅដែលងាយរងគ្រោះដោយសារគ្រឿងញៀនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវកោះអញ្ជើញម្ចាស់ទីតាំងទាំងនោះ មកធ្វើការពន្យល់ណែនាំឱ្យយកចិត្តទុកដាក់ក្នុងការងារគ្រប់គ្រងឱ្យបានហ្មត់ចត់ ព្រមទាំងធ្វើកិច្ចសន្យាសហការបង្ការ ទប់ស្កាត់មិនឱ្យមានគ្រឿងញៀននៅក្នុងទីតាំងរបស់ខ្លួន

- ត្រូវមានវិធានការដាច់ខាតដើម្បីបិទ ដកហូតច្បាប់អនុញ្ញាតធ្វើអាជីវកម្មមួយរយៈ ឬជាស្ថាពរ ចំពោះទីតាំង អាជីវកម្មណាដែលពិនិត្យឃើញថាមានសកម្មភាពជួញដូរ ប្រើប្រាស់គ្រឿងញៀន

- អគ្គនាយកដ្ឋានពន្ធនាគារត្រូវបន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែដោយមិនឱ្យមានការលួចនាំចូលសារធាតុញៀនផ្តល់ឱ្យពិរុទ្ធជន ឬទណ្ឌិត ឬទំនាក់ទំនងពីក្នុងទៅក្រៅ ពាក់ព័ន្ធបញ្ហាគ្រឿងញៀន។ ជាមួយនោះ ពិចារណាលើកវិធានការក្នុងការគ្រប់គ្រងជនល្មើសដែលពាក់ព័ន្ធគ្រឿងញៀន ឬសេពគ្រឿងញៀន ដាច់ដោយឡែកពីទណ្ឌិត ឬពិរុទ្ធជនដទៃទៀត

- ត្រូវមានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ សហគមន៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសាធារណៈ រោងចក្រ សហគ្រាស ដើម្បីមានវិធានការក្នុងការបង្ការទប់ស្កាត់ឬអនុវត្តវិធានការរដ្ឋបាល ។

**៣. វិធានការអនុវត្តច្បាប់**

- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំកម្លាំងអនុវត្តច្បាប់ (នគរបាល កងរាជអាវុធហត្ថ យោធាព្រំដែន) មានវិធានការម៉ឺងម៉ាត់ក្នុងការស្វែងរកឱ្យឃើញ និងទប់ស្កាត់ការលួចលាក់នាំចូលគ្រឿងញៀនខុសច្បាប់ ឆ្លងកាត់ព្រំដែនចូលមកក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួន ឬឆ្លងកាត់ពីខេត្តមួយ ទៅខេត្តមួយទៀត

- ត្រូវជំរុញការបើកករណីតស៊ូ ស្រាវជ្រាវរកមុខមេខ្លោងនិងបណ្តាញជួញដូរគ្រឿងញៀនឆ្លងដែន បញ្ជូនទៅតុលាការផ្តន្ទាទោសតាមច្បាប់

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតពួកជួញដូរគ្រឿងញៀនជាក្រុមតូចៗ និងអនុវត្តវិធានការច្បាប់ឱ្យបានម៉ឺងម៉ាត់តឹងរឹងបំផុត

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតអ្នកប្រើប្រាស់គ្រឿងញៀន តាមវិធីសហការជាមួយអាណាព្យាបាល សាលារៀន ឬសហគមន៍ ដើម្បីអប់រំ ព្យាបាលនៅតាមសហគមន៍(ករណីស្រាល) ឬបញ្ជូនទៅមណ្ឌលព្យាបាលនិងស្តារនីតិសម្បទា (ករណីធ្ងន់ធ្ងរ) ករណីចាំបាច់អនុវត្តវិធានការដាក់ទណ្ឌកម្មក្រោម៤៨ម៉ោង ដោយឱ្យធ្វើការងារហត្ថកម្ម ឬអនាម័យតាមទីសាធារណៈ

- ត្រូវតាមដាន គ្រប់គ្រង និងបង្ក្រាបឱ្យបានម៉ឺងម៉ាត់នូវសកម្មភាពផលិត កែច្នៃគ្រឿងញៀនសំយោគ ការដាំដុះ ការចម្រាញ់ ការនាំចូលវត្ថុធាតុដើម ជាសារធាតុគីមីផ្សំ ដែលអាចច្នៃផលិតជាគ្រឿងញៀនសំយោគ ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យបានជាក់លាក់

- គណៈបញ្ជាការឯកភាពរដ្ឋបាល រាជធានី ខេត្ត ត្រូវធ្វើជាអ្នកសម្របសម្រួល ដើម្បីជំរុញកិច្ចពិគ្រោះពិភាក្សារវាងស្ថាប័នអយ្យការ តុលាការ ជាមួយអង្គភាពនគរបាល និងកងរាជអាវុធហត្ថ ដើម្បីធ្វើឱ្យកិច្ចសហការកាន់តែមានដំណើរការរលូន លុបបំបាត់និទណ្ឌភាព និងរិះរកវិធីដាក់បន្ទុកបន្ថែមស្ថានទម្ងន់ទោសដល់មេខ្លោង និងបណ្តាញជួញដូរគ្រឿងញៀន

- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានការិយាល័យ BLO ត្រូវសហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀន អគ្គស្នងការដ្ឋាននគរបាលជាតិ មានកិច្ចប្រជុំត្រួតពិនិត្យក្នុងមួយខែម្តង ជាមួយប្រធាននិងមន្ត្រីការិយាល័យ BLO ដើម្បីជំរុញលើកទឹកចិត្តឱ្យមានកិច្ចសហការរួម ក្នុងការផ្តល់ព័ត៌មាននិងផ្លាស់ប្តូរសភាពការណ៍ជាប្រចាំ។

- គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ត្រូវខិតខំសហការជាមួយភាគីឡាវ ដើម្បីផ្លាស់ប្តូរព័ត៌មាន និងសហការស៊ើបអង្កេតរកមុខសញ្ញា ឈានទៅបង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមព្រំដែន ។

### ៤. វិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

- អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីដំណើការរៀបចំបង្កើតមជ្ឈមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅកងពលលេខ១១ និងមជ្ឈមណ្ឌលជាតិបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មនៅខេត្តព្រះសីហនុ តាមគោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល

- ក្រសួងសុខាភិបាល ត្រូវខិតខំលើកកម្ពស់សមត្ថភាពនិងពង្រីកសេវាបន្សាប ព្យាបាលដោយផ្អែកលើសហគមន៍ នៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ដើម្បីចូលរួមចំណែកកាត់បន្ថយការរាលដាលនៃការប្រើប្រាស់គ្រឿងញៀននៅតាមមូលដ្ឋាន

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពង្រឹងនិងពង្រីកសមត្ថភាពមណ្ឌលបណ្តោះអាសន្ន សម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋបន្ថែមទៀត ដើម្បីត្រៀមទទួលជនរងគ្រោះតាមការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ក្នុងយុទ្ធនាការនេះ

- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមានយន្តការគ្រប់គ្រងអ្នកញៀនគ្រឿងញៀនដែលមិនទាន់ទទួលបានការព្យាបាល ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យទៅទទួលយកការព្យាបាល និងត្រូវចាត់វិធានការតាមដានគ្រប់គ្រងចំពោះអ្នកចាកចេញពីមណ្ឌលព្យាបាលស្តារនីតិសម្បទា ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យវិលត្រឡប់ទៅសេពគ្រឿងញៀនវិញ

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាព និងលើកសំណើដើម្បីបង្កើតនូវមណ្ឌលបណ្ដោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅមូលដ្ឋានរបស់ខ្លួន។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ**

- អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននិងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវបន្តបើកទូលាយកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយប្រទេសជិតខាង ក៏ដូចជាអង្គការអន្តរជាតិសំខាន់ៗ ដើម្បីក្តាប់ជាប់និន្នាការប្រែប្រួលតាមដំណាក់កាលនីមួយៗ ក្តាប់របៀងខ្សែរយៈ និងបែបផែនសកម្មភាពរបស់ពួកឧក្រិដ្ឋជនគ្រឿងញៀន សំដៅមានវិធានការម្ចាស់ការទប់ស្កាត់ បង្ក្រាបបានទាន់ពេល ក្នុងនោះ យកចិត្តទុកដាក់ទាំងកិច្ចសហប្រតិបត្តិការថ្នាក់ជំនាញ និងមន្ត្រី BLO ដែលឈរជើងតាមព្រំដែន

- អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវបើកទូលាយកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានចារកម្ម ផ្លាស់ប្តូរព័ត៌មានករណីរឿងជាមួយអង្គការ UNODC INTERPOL និងជាមួយស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសនានា ជាពិសេស បណ្តាប្រទេសដែលជាប្រភពនៃការនាំចូលគ្រឿងញៀនឆ្លងកាត់កម្ពុជា ដើម្បីមានវិធានការក្នុងការបង្ក្រាបអង្គការចាត់តាំង ឬបណ្តាញជួញដូរគ្រឿងញៀនជាអន្តរជាតិឱ្យដល់ឫសគល់ ។

III. **ការចាត់តាំងអនុវត្ត**

១. យុទ្ធនាការនេះ ដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន** និង **ឯកឧត្តម កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**ជាអនុប្រធាន** ដោយប្រើប្រាស់យន្តការនានា ដែលបានបង្កើតកន្លងមកទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាព។

២.បង្កើតលេខាធិការដ្ឋាន ដើម្បីជាជំនួយការក្នុងការដឹកនាំអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។ លេខាធិការដ្ឋានេះ មានទីស្នាក់ការនៅអគ្គស្នងការដ្ឋាននគរបាលជាតិ និងមានសមាសភាពតំណាងមកពី៖ ក្រសួងយុត្តិធម៌ ក្រសួងអប់រំយុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងព័ត៌មាន, ក្រសួងធម្មការនិងសាសនា, ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍, ក្រសួងទេសចរណ៍, អគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, អគ្គនាយកដ្ឋានអន្តោប្រវេសន៍, អគ្គនាយកដ្ឋានពន្ធនាគារ, បញ្ជាការ-ដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

៣.លេខាធិការដ្ឋានត្រូវធ្វើរបាយការណ៍បូកសរុប ដើម្បីបម្រើការប្រជុំដឹកនាំត្រួតពិនិត្យលទ្ធផលនៃការអនុវត្តន៍យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនរៀងរាល់សប្តាហ៍ ខែ ត្រីមាស និងបូកសរុបដកពិសោធន៍ បញ្ចប់យុទ្ធនាការលើកទី១។

៤.ផ្អែកលើផែនការនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវកសាងផែនការជាក់ស្តែងតាមវិស័យ និងតាមភូមិសាស្ត្រនីមួយៗ សម្រាប់ចូលរួមអនុវត្តតាមតួនាទី ភារកិច្ចរៀងៗខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

៥.ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របដល់អង្គភាព និងបុគ្គលដែលមានស្នាដៃល្អក្នុងការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន និងមានវិធានការអនុវត្តវិន័យម៉ឺងម៉ាត់ចំពោះមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈអភិបាលរាជធានី ខេត្ត ទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៣៥០ សហវ.ប្រក

# ប្រកាសរួម

## ស្ដីពី

## ការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងសុខាភិបាល

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងឱសថ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០០៤៤ អនក្រ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីទិដ្ឋាការ-បញ្ជិកាឱសថ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងលក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- បានឃើញសេចក្តីសម្រេចលេខ ០៩៧ គ.ប.អវ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយបានសម្រេចកំណត់ការបង់ថ្លៃរបស់និស្សិតសម្រាប់រៀបចំការប្រឡងថ្នាក់ជាតិជ្រើសរើសនិស្សិតចូលរៀន កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងក្នុងវិស័យសុខាភិបាល ចំនួន ១២០.០០០(ដប់ពីរម៉ឺន) រៀល សម្រាប់និស្សិតម្នាក់
